ភ្នំពេញ, ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន

## អនុស្សរណៈស្តីពីភាពជាដៃគូយុទ្ធសាស្ត្ររវាងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុននិងកំពង់ផែស្វយ័តក្រុងព្រះសីហនុ

## -លើកកម្ពស់ការអភិវឌ្ឍកំពង់ផែនិងភស្តុភាកម្មក្នុងប្រទេសកម្ពុជា-

នាថ្ងៃទី៣ ខែមិថុនា **ឯកឧត្តម លូ គីមឈន់** ប្រធានអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ និងលោក Shigenori OGAWA អគ្គនាយកនៃនាយកដ្ឋានអាស៊ីអាគ្នេយ៍និងប៉ាស៊ីហ្វិករបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) បានចុះហត្ថលេខាលើអនុស្សរណៈស្តីពីភាពជាដៃគូយុទ្ធសាស្ត្រ នៅការិយាល័យកណ្តាល JICA ក្នុងទីក្រុងតូក្យូ ប្រទេសជប៉ុន។

អនុស្សរណៈស្តីពីភាពជាដៃគូយុទ្ធសាស្ត្រត្រូវបានរៀបចំឡើងក្នុងគោលបំណងពង្រឹង និងពង្រីកភាពជាដៃគូរវាង JICA និងកំពង់ផែស្វយ័តក្រុងព្រះសីហនុ ដើម្បីលើកកម្ពស់ការអភិវឌ្ឍកំពង់ផែ និងភស្តុភាកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៃប្រទេសកម្ពុជា។ កំពង់ផែស្វយ័តក្រុងព្រះសីហនុគឺជាកំពុងផែសមុទ្រទឹកជ្រៅតែមួយគត់ក្នុងប្រទេសកម្ពុជា ហើយកំពង់ផែនេះបានដើរតួជាមជ្ឈមណ្ឌលភស្តុភារកម្មសំខាន់ក្នុងការចូលរួមដល់ការអភិវឌ្ឍប្រទេសកម្ពុជា។ ចាប់តាំងពីឆ្នាំ១៩៩៩មក JICAបានផ្តល់កម្ចីហិរញ្ញប្បទាន ហិរញ្ញប្បទានឥតសំណង កិច្ចសហប្រតិបត្តិការបច្ចេកទេស និងបន្តផ្តល់ការគាំទ្រនានាដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងសមត្ថភាពកំពង់ផែ។

ផ្អែកលើការរីកចម្រើនផ្នែកសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា កំពង់ផែស្វយ័តក្រុងព្រះសីហនុនឹងក្លាយទៅជាមជ្ឈមណ្ឌលភស្តុភារកម្មក្នុងស្រុកនិងតំបន់យ៉ាងសំខាន់ ដែលក្នុងនោះចំនួនកុងតេន័រឆ្លងកាត់សរុប បានកើនឡើងពីចំនួន ២៩០ ០០០TEUs ក្នុងឆ្នាំ២០១៣ ដល់ ៥៩០ ០០០TEUs ក្នុងឆ្នាំ២០១៨។ ទន្ទឹមនឹងនេះ វាមានសារៈសំខាន់ណាស់ក្នុងការធ្វើការអភិវឌ្ឍកំពង់ផែស្វយ័តក្រុងព្រះសីហនុ ហើយការពង្រឹងបន្ថែមលើប្រតិបត្តិការនិងការគ្រប់គ្រងកំពង់ផែនិងតំបន់សេដ្ឋកិច្ចពិសេសក៏មានសារៈសំខាន់ផងដែរ។

ក្នុងជំនួបទ្វេភាគីរវាង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **ឯកឧត្តម** Shinzo ABE នាយករដ្ឋមន្ត្រីនៃប្រទេសជប៉ុន កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩ កន្លងមកនេះ ប្រទេសជប៉ុនបានប្តេជ្ញាបន្តផ្តល់ការគាំទ្រដល់ការអភិវឌ្ឍពង់ផែស្វយ័តក្រុងព្រះសីហនុបន្ថែមទៀត ក្នុងនោះរួមមានទាំងការរៀបចំផែនការមេសម្រាប់ការអភិវឌ្ឍកំពង់ផែផងដែរ។ ក្នុងន័យនេះ JICA នឹងបន្តកិច្ចសហប្រតិបត្តិការ តាមរយៈការផ្តល់កម្ចីហិរញ្ញប្បទានសម្រាប់គម្រោង "អភិវឌ្ឍចំណតកុងតេន័រថ្មីរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ" និងហិរញ្ញប្បទានឥតសំណងសម្រាប់គម្រោង "ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យអគ្គីសនីនៅកំពង់ផែដើម្បីការធ្វើទំនើបកម្មកំពង់ផែ"។ មិនតែប៉ុណ្ណោះ JICA នឹងចូលរួមលើកកម្ពស់ពាណិជ្ជកម្មក្នុងតំបន់អាស៊ាននិងតំបន់ឥណ្ឌា-ប៉ាស៊ីហ្វិក តាមរយៈការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូរជាមួយកំពង់ផែស្វយ័តក្រុងព្រះសីហនុ។

[1] The amount of cargo in a 20-foot-long container
[2] Press Release on Sihanoukville Port New Container Terminal Development Project
[3] Press Release on the Project for Port EDI for Port Modernization
[4] Share Transfer of Sihanoukville Autonomous Port – Cambodia

សំរាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងលោក ស៊ុន វាសនា មន្ត្រីការិយាល័យ JICA ប្រចាំនៅកម្ពុជា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៦៧៣/៤ ឬ ០១២ ៨៥១ ៩៤៤ អ៊ីម៉ែល Soun-Veasna@jica.go.jp.